ALiSEA
AGROECOLOGY LEARNING ALLIANCE
IN SOUTH EAST ASIA

បណ្តាញកសិអេកូឡូស៊ី
នៅកម្ពុជា





# បណ្តាញកសិអេកូឡូស៊ីនៅកម្ពុជា

## តើ បណ្តាញកសិអេកូឡូស៊ី ( ALISEA ) ជានរណា ?

បណ្តាញកសិអេកូឡូស៊ី ហៅកាត់បណ្តាញ អាលីសៀ (ALiSEA) ជាបណ្តាញសមាជិកភាពថ្នាក់តំបន់មួយដែលផ្សារភ្ជាប់ភាគីពាក់ព័ន្ធក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងគោលដៅលើកកម្ពស់កសិអេកូឡូស៊ី និងប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព។ បណ្តាញ ALiSEA ផ្សារភ្ជាប់ទំនាក់ទំនងរវាងកសិករ អ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកបង្កើតគោលនយោបាយ ឱ្យធ្វើការរួមគ្នាដើម្បីចែករំលែកចំណេះដឹង និងជំរុញវិវឌ្ឍនាការកសិអេកូឡូស៊ី។

## បេសកកម្ម

ពង្រឹងវិស័យកសិកម្មប្រកបដោយនិរន្តរភាពតាមរយៈការចែករំលែកចំណេះដឹង ការសហការ និងជំរុញនវានុវត្តន៍នៃការអនុវត្តកសិកម្មនៅទូទាំងអាស៊ីអាគ្នេយ៍។

## ចក្ខុវិស័យ

ជំរុញតំបន់អាស៊ីអាគ្នេយ៍ទៅជាតំបន់មួយ ដែលកសិអេកូឡូស៊ី ដើរតួសំខាន់ក្នុងការជំរុញការផ្លាស់ប្តូរប្រព័ន្ធស្បៀងអាហារ ដើម្បីមនុស្ស និងប្រព័ន្ធអេកូឡូស៊ី។

## គុណតម្លៃ

- ការសហការ និងភាពជាដៃគូ
- ការចែករំលែកចំណេះដឹង
- និរន្តរភាព និងសមធម៌
- នវានុវត្តន៍ និងការសិក្សាស្រាវជ្រាវ

## ប្រវត្តិនៃបណ្តាញ ALISEA

បណ្តាញ ALiSEA បានផ្តួចផ្តើមដំបូងក្រោមគម្រោង ACTAE (២០១៥-២០១៨) ដើម្បីលើកកម្ពស់កសិអេកូឡូស៊ី នៅប្រទេសកម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា និងថៃ។ បច្ចុប្បន្ន បណ្តាញ ALiSEA បានអភិវឌ្ឍ និងកែលម្អនូវប្រតិបត្តិការ និង រចនាសម្ព័ន្ធ ដើម្បីឱ្យការអនុវត្តសកម្មភាពមានភាពល្អប្រសើរឡើង។

ដំណាក់កាលសំខាន់នៃការវិវត្តរបស់បណ្តាញ ALiSEA៖

**ដំណាក់កាលផ្តួចផ្តើមគំនិត (២០១៥-២០១៦)៖** បានប្រមូលផ្តុំចំនុចអាទិភាពក្នុងកម្រិតថ្នាក់ជាតិ គូសផែនទីលើភាគីពាក់ព័ន្ធ និងកំណត់វិធីសាស្ត្រផ្សព្វផ្សាយ។

**លក្ខខណ្ឌនៃការបើកដំណើរការ (២០១៦-២០១៨)៖** ពង្រឹងការដឹកនាំបណ្តាញ គាំទ្រការស្រាវជ្រាវ និងផ្តល់កញ្ចប់មូលនិធិខ្នាតតូច ដើម្បីគាំទ្រសមាជិកក្នុងការអនុវត្តកសិអេកូឡូស៊ី។

**មូលធននីយកម្ម (២០១៨-២០១៩)៖** ចងក្រងឯកសារដែលបានពីបទពិសោធន៍ជាក់ស្តែង ផលិតមាតិកាលើប្រព័ន្ធផ្សព្វផ្សាយ និងសហការរៀបចំវេទិកាអនាគតកសិអេកូឡូស៊ីក្នុងតំបន់។

✳ **ការពង្រីកវិសាលភាព (២០១៩-២០២៦)៖** បណ្តាញ ALiSEA ពង្រីកវិសាលភាពនៃការអនុវត្តសកម្មភាពជាមួយសមាជិក រួមមាន សិក្ខាសាលាទ្រឹស្តីនៃការផ្លាស់ប្តូរ កិច្ចសន្ទនាគោលនយោបាយ ការសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការអភិវឌ្ឍមជ្ឈមណ្ឌលចំណេះដឹង ដោយមានការគាំទ្រពីគម្រោងអាសិត (ASSET) គម្រោង PArTNER របស់អង្គការUni4Coop (Eclosio & Louvain Cooperation) និងកម្មវិធីលើកកម្ពស់កសិអេកូឡូស៊ី (APP)។ បច្ចុប្បន្ន បណ្តាញកំពុងបន្តអភិវឌ្ឍសកម្មភាពរបស់ខ្លួនទៅមុខបន្ទៀតដើម្បីសម្រេចបាននូវទិសដៅយុទ្ធសាស្ត្រសម្រាប់សមាជិក។



រូបភាពក្នុងសិក្ខាសាលាផ្តល់ព័ត៌មានលើកញ្ចប់មូលនិធិខ្នាតតូចរបស់ALiSEA ឆ្នាំ ២០២៤
ភ្នំពេញ ៣០ សីហា ២០២៤

## សមាជិកនៅប្រទេសកម្ពុជា

សមាជិកនៃបណ្តាញ ALiSEA មានលក្ខណៈចម្រុះ រួមមាន អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល អង្គការកសិករ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងស្ថាប័នរាជរដ្ឋាភិបាល ដែលមានសកម្មភាព និងចក្ខុវិស័យរួមគ្នា ក្នុងការអនុវត្ត និងផ្សព្វផ្សាយកសិអេកូឡូស៊ី។ បណ្តាញ ALiSEA មាន សមាជិកនៅក្នុងប្រទេសកម្ពុជាប្រមាណ ៨០ ស្ថាប័ន។



***Figure 4:** https://ali-sea.org/our-members/*

## តួនាទីរបស់សមាជិក

- ✅ គោរពគោលការណ៍របស់បណ្តាញ ALiSEA រួមបញ្ចូលទាំង បេសកកម្ម ចក្ខុវិស័យ និង គោលបំណង
- ✅ មានភាពសកម្មក្នុងការចូលរួម ជាមួយសកម្មភាពរបស់បណ្តាញ៖ ការសហការ ចូលរួមចែករំលែក និងរៀនសូត្រពីសមាជិកដទៃទៀត ឬ ពីដៃគូសហការរបស់បណ្តាញ ALiSEA

## លក្ខខណ្ឌ នៃការចូលរួមជាសមាជិក

- ✳ **ប្រភេទស្ថាប័ន** ៖ អង្គការកសិករ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ បណ្តាញ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន ស្ថាប័នរាជរដ្ឋាភិបាល
- ✳ **ទីតាំងភូមិសាស្ត្រ** ៖ តំបន់មេគង្គ (កម្ពុជា)
- ✳ **ចូលរួមដោយស្ម័គ្រចិត្ត**
- ✳ **ឯកសារតម្រូវ**
  - លិខិតចំណាប់អារម្មណ៍នៃការចូលរួម ១ច្បាប់ ដែលមានហត្ថលេខា ឬត្រារបស់ស្ថាប័ន
  - របាយការណ៍បង្ហាញពីសកម្មភាពនានា ឬ របាយការណ៍រីកចម្រើនប្រចាំឆ្នាំទាក់ទងនឹងកសិអេកូឡូស៊ី
  - ព័ត៌មានស្ថាប័ន និងរចនាសម្ព័ន្ធស្ថាប័ន
  - តំណភ្ជាប់ទៅកាន់បណ្តាញសង្គមស្ថាប័នរបស់អ្នក



រូបភាពវគ្គបណ្តុះបណ្តាលការប្រើប្រាស់ដំណាំគម្របដីក្នុងប្រព័ន្ធផលិតកម្មស្រូវ (ASSET Flagship)
ស្រុករវៀង ខេត្ត ព្រះវិហារ ០៨ វិច្ឆិកា ២០២៤

**ផ្ញើឯកសារទាំងអស់ទៅកាន់ លេខាធិការដ្ឋាន់ជាតិរបស់បណ្តាញ**

## ចូលរួមជាមួយ ALiSEA ទទួលបានឱកាស

- ✅ **ចំពោះស្ថាប័ន៖** ទទួលបានកញ្ចប់មូលនិធិខ្នាតតូច ការបណ្តុះបណ្តាល និងធនធាន
- ✅ **ចំពោះបុគ្គល:** ផ្សាភ្ជាប់ទំនាក់ទំនងជាមួយអ្នកអនុវត្ត
- ✅ **ចំពោះអ្នកបង្កើតគោលនយោបាយ:** ចូលរួមកិច្ចសន្ទនាគោលនយោបាយក្នុងតំបន់


រូបភាពក្នុងចម្ការសណ្តែកដី ដែលដាំជាដំណាំឆ្លាស់រងជាមួយដំឡូងមី
បាត់ដំបង ០៣ កញ្ញា ២០២៥

តាមរយៈកិច្ចពិភាក្សាជាមួយសមាជិកនៅក្នុងសិក្ខាសាលាទ្រឹស្តីនៃការផ្លាស់ប្តូរក្នុងឆ្នាំ២០២២ ក្រោមការគាំទ្រពីគម្រោង ASSET សមាជិកបណ្តាញ ALiSEA បានកំណត់ផ្លូវដើររួមមួយ ដែលជាផ្នែកមួយក្នុងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំឱ្យសម្រេចបាននូវចក្ខុវិស័យនៃវិវឌ្ឍនាការកសិអេកូឡូស៊ី នាពេលអនាគតក្នុងឆ្នាំ២០៤០។

(តារាងខាងក្រោមបង្ហាញពីលទ្ធផលនៃសិក្ខាសាលាទ្រឹស្តីនៃការផ្លាស់ប្តូរ និងផ្លូវដើររបស់បណ្តាញ ALiSEA ពីឆ្នាំ ២០២២ ដល់ ២០៤០)

## ផ្លូវដើរនៅកាន់កសិអេកូឡូស៊ីនៅកម្ពុជា ( ប្រភព ALISEA )



២០២២ → ២០២៥ → ២០៣០ → ២០៣៥ → ២០៤០

| បច្ចុប្បន្ន ( និន្នាការ ឧបសគ្គ ឱកាស ) | វិវឌ្ឍនាការ | ចក្ខុវិស័យ ២០៤០ |
|---|---|---|
| ១. ខ្វះខាតចំណេះដឹង និងបទពិសោធន៍នៃការអនុវត្ត | • ការកសាងសមត្ថភាពដល់កសិករ អ្នកផ្សព្វផ្សាយឬផ្តល់សេវាកម្មកសិកម្ម និងអ្នកពាក់ព័ន្ធ<br>• បង្កើតឯកសារ សៀវភៅណែនាំបណ្តុះបណ្តាល ឧបករណ៍នានា ដើម្បីផ្សព្វផ្សាយកសិអេកូឡូស៊ី<br>• ផ្តល់នូវការច្នៃប្រឌិត (កសិដ្ឋានបង្ហាញ ប្រព័ន្ធឌីជីថល កម្មវិធីសិក្សា) | ១. កសិករ ៧៥% យល់ដឹងពីកសិអេកូឡូស៊ី និង ៥០% បានអនុវត្តតាមគោលការណ៍កសិអេកូឡូស៊ី |
| ២. ខ្វះខាតនូវតម្លៃបុព្វលាភ (តម្លៃបន្ថែម)សម្រាប់ផលិតផលកសិអេកូឡូស៊ី | • គាំទ្រទីផ្សារកសិអេកូឡូស៊ី ដល់សហគមន៍កសិកម្ម (ផលិត និងលក់ក្នុងស្រុក) ទីផ្សារក្នុងសហគមន៍ និងទីផ្សារឌីជីថល<br>• ម៉ាកសំគាល់ផលិតផលកសិអេកូឡូស៊ី និងបង្កើនការយល់ដឹងដល់អ្នកប្រើប្រាស់<br>• យុទ្ធនាការផ្សព្វផ្សាយផលិតផលកសិអេកូឡូស៊ី (សិក្ខាសាលា ឬប្រព័ន្ធឌីជីថល)<br>• ការកាត់បន្ថយថ្លៃដើម ក្នុងខ្សែច្រវាក់ផលិតកម្ម | ២. ទីផ្សារក្នុងស្រុកដោយស្របតាមគោលការណ៍សេដ្ឋកិច្ចចក្រា សមភាព បំពេញតម្រូវការខ្លួនឯងគ្រប់គ្រាន់ និងផលិតផលមានតម្លៃសមរម្យ |
| ៣. មិនមានគោលនយោបាយគាំទ្រលើកទឹកចិត្តដល់កសិករអនុវត្តកសិអេកូឡូស៊ី | • ផ្សារភ្ជាប់/បញ្ចូលតួអង្គកសិអេកូឡូស៊ីទាំងអស់ទៅក្នុងវេទិកាដែលមានស្រាប់ រួមមានវេទិការកសិករ CASIC និង ALiSEA<br>• រៀបចំយន្តការហិរញ្ញវត្ថុ កម្ចី ប្រាក់លើកទឹកចិត្ត សម្រាប់កសិករអនុវត្តកសិអេកូឡូស៊ី<br>• បង្កើតយន្តការក្នុងការទិញផលិតផលកសិអេកូឡូស៊ីសម្រាប់សេវាសាធារណៈ (លទ្ធកម្មសាធារណៈ) | ៣. គោលនយោបាយពេញលេញក្នុងការគាំទ្រកសិអេកូឡូស៊ី |

## សកម្មភាពស្នូលទាំង ៥

### ចែករំលែកចំណេះដឹង

ជាស្ពានផ្សារភ្ជាប់ទំនាក់ទំនងរវាងសហគមន៍ និងការស្រាវជ្រាវតាមរយៈមជ្ឈមណ្ឌលចំណេះដឹង

**ជាង ១០០០ ប្រភពឯកសារ**

### ការផ្សព្វផ្សាយ

ការលើកកម្ពស់ការអនុវត្ត កសិអេកូឡូស៊ី តាមរយៈសិក្ខាសាលាតាមប្រព័ន្ធអនឡាញ និងយុទ្ធនាការនានា

**សិក្ខាសាលាតាមប្រព័ន្ធអនឡាញ**

### កិច្ចសន្ទនាគោលនយោបាយ

ចូលរួមជាមួយអ្នកបង្កើតគោលនយោបាយកសិកម្ម ដើម្បីបង្កើតការផ្លាស់ប្តូរជាប្រព័ន្ធ

**ជ្រៀតចូលគោលនយោបាយក្នុងតំបន់**

### ពង្រឹងសមត្ថភាព

សិក្ខាសាលាបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញសម្រាប់អ្នកអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព

**បន្តអនុវត្តជាបន្តបន្ទាប់**

### មូលនិធិខ្នាតតូច

ផ្តល់មូលនិធិខ្នាតតូចដល់គម្រោងនវានុវត្តភាពនៃកសិអេកូឡូស៊ីនៅទូទាំងតំបន់

**១៣០ ពាន់អ៊ឺរ៉ូ**

## តើឯកសារអ្វីខ្លះ ដែលអាចរួមចំណែកដល់មជ្ឈមណ្ឌលចំណេះដឹង ALiSEA ?

- ALiSEA ស្វាគមន៍រាល់ការចូលរួមចំណែកទាំងអស់ពីសមាជិក ដៃគូ ឬសាធារណៈជន ដែលចាប់អារម្មណ៍ក្នុងការជំរុញនិងចែករំលែក ចំណេះដឹងកសិអេកូឡូស៊ី។
- **ប្រភេទឯកសារ៖** គោលការណ៍ណែនាំបច្ចេកទេស សេចក្ដីសង្ខេបនៃការស្រាវជ្រាវ សេចក្ដីសង្ខេបនៃការអនុវត្ត ការអនុវត្តល្អបំផុត វីដេអូ ព្រឹត្តិការណ៍ និងឬឯកសារផ្សេងទៀត។

## តើអ្នកអាចរកឃើញអ្វីខ្លះនៅលើមជ្ឈមណ្ឌលចំណេះដឹង ALiSEA ?

- ការយល់ដឹងអំពីទិដ្ឋភាពផ្សេងៗនៃការវិវឌ្ឍនាការកសិអេកូឡូស៊ី និងវិធានក្នុងការគាំទ្រវានៅកម្រិតអនុវត្តជាក់ស្ដែង និងគោលនយោបាយ។
- ប្រភេទឯកសារផលិតផលចំណេះដឹង បណ្ណាល័យឯកសារ ផែនទី ការមើលឃើញទិន្នន័យ និងបញ្ជីឈ្មោះអ្នកជំនាញកសិអេកូឡូស៊ី។




បណ្ដាញ ALiSEA ជាវេទិកាសំខាន់មួយសម្រាប់ការកសាងសមត្ថភាព និងសម្របសម្រួលការផ្លាស់ប្ដូរចំណេះដឹងកសិអេកូឡូស៊ី។ ក្នុងនោះ បណ្ដាញ ចូលរួមចំណែកសំខាន់ក្នុងការលើកកម្ពស់កសិអេកូឡូស៊ីនៅក្នុងតំបន់ តាមរយៈការកៀរគរតួអង្គពាក់ព័ន្ធដែលមានចម្រុះភាព ជំរុញកិច្ចសហការ និងលើកកម្ពស់វប្បធម៌នៃការសិក្សារៀនសូត្ររួមគ្នា។

តាមរយៈការលើកកម្ពស់ការផ្សព្វផ្សាយ និងការយល់ដឹងអំពីអំពីគោលការណ៍កសិអេកូឡូស៊ី បណ្ដាញ ALiSEA មានគោលបំណងសម្របសម្រួលនូវការដាក់បញ្ចូលបច្ចេកទេសកសិអេកូឡូស៊ីទៅដល់អ្នកអនុវត្តផ្ទាល់ និងអ្នកបង្កើតគោលនយោបាយសាធារណៈ។ ទន្ទឹមនឹងនេះ បណ្ដាញក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការរំលេចអំពីកសិអេកូឡូស៊ី ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ តាមរយៈការផ្សារភ្ជាប់ជាមួយប្រព័ន្ធផ្សព្វផ្សាយ និងបណ្ដាញទំនាក់ទំនងផ្សេងៗ។

បណ្ដាញ ALiSEA ប្រឹងប្រែងកំណត់តម្រូវការរបស់សមាជិកអំពីកសិអេកូឡូស៊ីដើម្បីជំរុញការផ្លាស់ប្ដូរចំណេះដឹង ដោយការទាញយកពហុបទពិសោធន៍ពីសមាជិកបណ្ដាញ។ ក្រៅពីនេះបណ្ដាញក៏គាំទ្រសាកល្បងនូវ នវានុវត្តន៍កសិអេកូឡូស៊ី តាមរយៈបរិបទផ្សេងៗដូចជា សហសិក្សាស្រាវជ្រាវ ចែករំលែកលទ្ធផល និងសហការរួមគ្នាចងក្រងមេរៀនទទួលបានពីការអនុវត្ត។

បណ្ដាញក៏បានរួមគ្នា ជាមួយស្ថាប័នដែលជាសមាជិក ក្នុងការចងក្រងឯកសារគំនិតផ្ដួចផ្ដើមនៅមូលដ្ឋាន និងអនុសាសន៍នានា ដោយផ្អែកលើភស្តុតាងជាក់ស្ដែង។ ដោយយកចិត្តទុកដាក់ប្រកបដោយបរិយាប័ន្ន សហសកម្មភាព និងយន្តការការចូលរួមរបស់សមាជិកបណ្ដាញ ALiSEA បានកំណត់ទិសដៅយុទ្ធសាស្រ្តរបស់បណ្ដាញដោយមានការចូលរួមពីសមាជិក និងពង្រីកការអនុវត្តកសិអេកូឡូស៊ីក្នុងតំបន់។

## ស្វែងយល់បន្ថែម

ALiSEA's Facebook

ALiSEA's Website



**ALiSEA National Executive Team**

- **Ms. Sok Chanraksmey**, ALiSEA National Secretary, DPA, <sok.chanraksmey@dpacam.org>
- **Mr. Hou Sorith**, ALiSEA National Knowledge Management Coordinator, ECOLAND, <hsorith@rua.edu.kh>
- **Mr. Sok Sotha**, ALiSEA National Policy Coordinator, CFAP, <soksotha.cam@gmail.com>

**Date of publication:** October 2025

www.ali-sea.org

**ALiSEA Coordination Team**

- Regional Coordinator: **Lucie Reynaud** <Reynaud@gret.org>
- Regional Deputy Coordinator: **Mr. Pat Sovann** <pat.cambodia@gret.org>

Implemented by:

Supported by:

Funded by:

This document has been produced with the financial assistance of the Directorate-General for Development Cooperation and Humanitarian Aid (DGD), Swiss Development (SDC), the French Development Agency (AFD), the European Union (EU), and the French Facility for Global Environment (FFEM). The views expressed herein can in no way be taken to reflect the official opinion of the DGD, SDC, AFD, EU, or FFEM.